Khmer | ភាសាខ្មែរ

## ភ្លៀងច្រើន និងអាកាសធាតុកាន់តែក្ដៅ គឺជាលក្ខខណ្ឌបង្កាត់តពូជដ៏ល្អបំផុតសម្រាប់សត្វមូស។

ការនេះអាចមានន័យថាសត្វមូសកាន់តែច្រើន ហើយហានិភ័យនៃជំងឺនានាក៏កើនឡើងដែរ ដែលសត្វមូសចម្លងជំងឺនានាដូចជាវីរុសព្រៃឈើ Barmah (Barmah Forest), វីរុសទន្លេ Ross (Ross River), វីរុសបង្ករោគរលាកខួរក្បាលជប៉ុន ហើយនិងវីរុសរលាកខួរក្បាល Murray Valley។

កិច្ចការពារដ៏ល្អបំផុតប្រឆាំងទល់នឹងសត្វមូសដែលចម្លងជំងឺនានា គឺជៀសវាងកុំឱ្យការខាំកើតមានឡើង។



# ត្រូវត្រៀមខ្លួន

## សម្រាប់មូស



សម្រាប់ព័ត៌មានបន្ថែម ស្ដីពីរបៀបដែលអ្នកអាចការពារ ខ្លួនអ្នកកុំឱ្យសត្វមូស ខាំ និងជំងឺនានាបណ្ដាលមកពីសត្វមូស សូមចូលមើល **www.betterhealth.vic.gov.au/protect-yourself-mosquito-borne-disease។**

ដើម្បីទទួលបានឯកសារនេះជាទម្រង់មួយផ្សេងទៀត សូមអ៊ីមែលទៅ pph.communications@dhhs.vic.gov.au។

Authorised and published by the Victorian Government, 1 Treasury Place, Melbourne.

© State of Victoria, Australia, Department of Health, December 2022

បោះពុម្ពដោយ Finsbury Green, Melbourne (2211311).

VICTORIA State Government

# ត្រូវត្រៀមខ្លួន

## សម្រាប់មូស

## របៀបការពារខ្លួនអ្នក និង គ្រួសាររបស់អ្នកពីសត្វមូស ដែលចម្លងជំងឺនានា។



# របៀបការពារខ្លួនអ្នកកុំឱ្យសត្វមូសខាំ



ប្រើថ្នាំបណ្ដេញសត្វមូសដែលមានសារធាតុ picaridin ឬ DEET នៅលើស្បែកដែលមិនបានគ្របដណ្ដប់ទាំងអស់។



ពាក់សម្លៀកបំពាក់វែង ធូររលុងសមស្រប ហើយមានពណ៌ជះពន្លឺ ដើម្បីគ្របដណ្ដប់ស្បែករបស់អ្នក ក៏ដូចជាស្បែកជើង បិទជិតមានស្រោមជើងផងដែរ។ សត្វមូស អាចខាំតាមរយៈសម្លៀកបំពាក់រឹតតឹង។



ព្យាយាមកំណត់សកម្មភាព នៅក្រៅអគារ ប្រសិនបើមាន សត្វមូសច្រើននៅទីនោះ។



យកទឹកកខ្វក់ចេញពីជុំវិញផ្ទះរបស់អ្នក ដើម្បីទប់ស្កាត់កុំឱ្យសត្វមូសបង្កាត់ពូជ។



ថ្នាំអុជបង្ហើរផ្សែងបណ្ដេញសត្វញមូសក៏អាចមានប្រសិទ្ធភាពផងដែរនៅក្នុងតំបន់តូចៗនៅក្រៅអគារ នៅទីកន្លែងដែលអ្នកប្រមូលផ្តុំគ្នា ដើម្បីអង្គុយ ឬបរិភោគ។



ប្រើថ្នាំបាញ់បណ្ដេញសត្វរុយលឿន ហើយដោតឧបករណ៍បណ្ដេញសត្វមូស នៅក្នុងអគារ។



ដេកនៅក្នុងមុងការពារសត្វ មូស ប្រសិនបើអ្នកមិន មាន សំណាញ់ការពារសត្វល្អិត។



ទប់ស្កាត់កុំឱ្យសត្វមូស ចូលមកខាងក្នុង ដោយប្រើ សំណាញ់ការពារសត្វរុយនៅលើបង្អួច និងទ្វារ។



## ការជ្រើសរើស ថ្នាំបណ្ដេញសត្វមូស

ថ្នាំបណ្ដេញសត្វមូសមានជាឡេ ជាតិអន្ទិល សារធាតុអេរ៉ូសូល និងស្នប់បាញ់។ ថ្នាំបណ្ដេញសត្វមូសដែលមានសារធាតុ **picaridin** ឬ **DEET (Diethyltoluamide)** គឺមានប្រសិទ្ធភាព បំផុត។ សម្រាប់មនុស្សភាគច្រើន ផលិតផលនានាដែលមានបង្គាប់ 10 ទៅ 20% គឺអាចការពារបាន។ បង្គាប់ថ្នាំបណ្ដេញសត្វមូសទាក់ទងនឹងភាពយូរអង្វែង មិនមែនប្រសិទ្ធភាពទេ។ ដូច្នេះត្រូវជ្រើសរើសបង្គាប់ទាបបំផុតសម្រាប់សេចក្ដីត្រូវការរបស់អ្នក និងលាបម្ដងទៀតនៅពេលត្រូវការ។ សម្រាប់មនុស្សភាគច្រើន, 10-20% គឺល្អសមស្រប។

## ប្រើថ្នាំបណ្ដេញសត្វមូស

ដូចឡេការពារកម្ដៅថ្ងៃដែរ ថ្នាំបណ្ដេញសត្វមូសមានប្រសិទ្ធភាព ប៉ុណ្ណោះប្រសិនបើលាបវានៅលើស្បែកដែលមិនបានគ្របដណ្ដប់ទាំងអស់។ ត្រូវមានបំណងលាបស្តើងៗ ជាស្រទាប់រាបស្មើទៅលើស្បែកដែលមិនបានគ្របដណ្ដប់ទាំងអស់។

ជាការសំខាន់ត្រូវលាបវាម្ដងទៀត ជាពិសេសក្រោយពីហែលទឹក ឬបែកញើស ដោយសារតែថ្នាំបណ្ដេញសត្វមូសមិនជ្រាប ទឹកទេ។

ត្រូវប្រុងប្រយ័ត្នជៀសវាងកុំឱ្យប៉ះភ្នែក និងមាត់របស់អ្នក នៅពេលលាប ព្រមទាំងកុំឱ្យក្មេងៗលាប ថ្នាំបណ្ដេញសត្វមូសដោយខ្លួនឯង។

សារធាតុ **DEET** អាចធ្វើឱ្យខូចខាតដល់សម្ភារប្លាស្ទិក ដូចជាផលិតផលសំលៀកមិនជ្រាបទឹក និងខ្សែនាឡិកា។ ប្ដូរទៅសារធាតុ **picaridin** ប្រសិនបើនេះជា ការព្រួយបារម្ភ។

សម្រាប់ក្មេងៗ សូមប្រើថ្នាំបណ្ដេញសត្វមូសរំអិលពីលើ ឬបាញ់ទៅក្នុងក្បុង ដៃរបស់អ្នក ហើយបន្ទាប់មកលាបទៅលើស្បែករបស់ពួកគេ។ ធ្វើតាមការណែនាំដែលមាននៅលើស្លាក។

# សម្អាតនៅជុំវិញផ្ទះរបស់អ្នក

សត្វមូសចូលចិត្តបង្កាត់កូននៅក្នុងទឹកកខ្វក់។ កាត់បន្ថយទឹកនៅក្នុងថ្លុក និងនៅជុំវិញសួនក្រោយផ្ទះ ពេលណាដែលអ្នកអាចធ្វើទៅបាន។



សម្អាតដោយយកទឹកចេញ សូម្បីតែដំណក់ទឹកតូចៗនៅក្នុងកង់ឡានចាស់ៗ ថូ ដាំដំណាំ ធុងទឹក និងរថសណ្ដោង។



ចាក់ចោល និងដាក់ជំនួស ទឹកថ្មីនៅក្នុងអាងទឹកបក្សី ចានគោមដាក់ទឹកឱ្យសត្វចិញ្ចឹម និង វត្ថុដាក់ទឹកផ្សេងៗ យ៉ាងហោចណាស់មួយសប្ដាហ៍ម្ដង។



កាត់ ស្មៅវែងៗ គុម្ពដំណាំតូចៗ និងគម្ពោតនានា។



រក្សាទបង្ហូរទឹក និងអាងហែលទឹករបស់អ្នកឱ្យបានស្អាត។



ពិនិត្យធុងទឹកឱ្យប្រាកដថាវាបិទជិត និងដាក់សំណាញ់ការពារកុំឱ្យសត្វមូសចូល និង/ឬ ដាក់សន្ទះបិទបើកនៅរាល់ពេលបើក រួមមានគម្របទប់ទឹកហៀរហូរ។